# សេចក្តីប្រកាសអាលម៉ាអាតាសន្និសីទអន្តរជាតិស្តីពី

# ការថែទាំសុខភាពបឋម

---

## នៅក្នុងការប្រជុំ អាលម៉ាអាតា

## នៅថ្ងៃទី ១២ កញ្ញា ១៩៧៨



**បកប្រែដោយៈ សកម្មភាពសង្គមដើម្បីសហគមន៍និងការអភិវឌ្ឍ**

# សេចក្តីផ្តើម

"សុខភាពសំដៅទៅលើ សុខុមាលភាពពេញលេញទាំងផ្នែករូបរាងកាយ សុខភាពចិត្ត និង សង្គមមិនមែនគ្រាន់តែអវត្តមាននៃជម្ងឺ ឬ ភាពឈឺចាប់បណ្តោះនោះទេ។ សុខភាពគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ហើយការទទួលបានសុខភាពកំរិតខ្ពស់បំផុតគឺជាគោលដៅដ៏សំខាន់នៅទូទាំងពិភពលោក ដែលការសម្រេចអោយបានគោលដៅនេះ ទាមទារអោយមានសកម្មភាពរបស់វិស័យច្រើនដូចជា វិស័យសង្គម និងសេដ្ឋកិច្ចបន្ថែមទៅលើវិស័យសុខាភិបាល" ត្រូវបាន ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងសេចក្តីប្រកាសអាលម៉ាអាលតា នៅក្នុងសិន្និសីទអន្តរជាតិពីការថែទាំសុខភាពបឋម នាឆ្នាំ១៩៧៨។ សេចក្តីប្រកាសដដែលនេះក៏បាន បញ្ជាក់ផងដែរពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាជនក្នុងការធ្វើផែនការ និងការអនុវត្តន៍ការថែទាំសុខភាពរបស់ពួកគេ។ ការជម្រុញអោយមាននូវការកាត់បន្ថយនូវវិសមភាពនៃការទទួលបានសេវាសុខភាពរវាងប្រទេសក្រីក្រ និងប្រទេសអភិវឌ្ឍន៍ក៏ត្រូវបានបញ្ជាក់ និង ចំណុចចំបងៗដែលជាអទិភាពផ្សេងទៀតផងដែរ។

សកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍន៍ បកប្រែសេចក្តីប្រកាសជាសកលនេះ ក្នុងគោលបំណងចូលរួមចំណែកផ្សព្វផ្សាយក្នុងការចូលរួមជាមួយនឹងការតាំងចិត្តរបស់រដ្ឋាភិបាល ព្រមទាំងភាគីផ្សេងៗទៀត ក្នុងការបន្តជម្រុញអនុវត្តនូវការតាំងចិត្តទៅដល់គោលដៅ។

# សេចក្តីប្រកាស អាលម៉ាអាលតា

# សន្និសីទអន្តរជាតិស្តីពី ការថែទាំសុខភាពបឋម នៅក្នុងការប្រជុំ អាលម៉ាអាតា

# នៅថ្ងៃទី ១២ កញ្ញា ១៩៧៨

សន្និសីទអន្តរជាតិស្តីពីការថែទាំសុខភាពបឋមនៅអាលម៉ាអាតា នៅថ្ងៃទី ១២ ខែកញ្ញា ក្នុងឆ្នាំ ១៩៧៨ បង្ហាញពីតម្រូវការនូវសកម្មភាពបន្ទាន់របស់រដ្ឋាភិបាលទាំងអស់ បុគ្គលិកសុខភាពនិងបុគ្គលិកធ្វើការងារអភិវឌ្ឍន៍ទាំងអស់ និង សហគមន៍ពិភពលោកដើម្បីការពារនិងលើកកម្ពស់សុខភាពរបស់មនុស្សទាំងអស់នៅក្នុងពិភពលោកដែលមានដូចតទៅៈ

## សេចក្តីប្រកាស

១. សន្និសីទ ធ្វើការបញ្ជាក់យ៉ាងច្បាស់ថា សុខភាព សំដៅទៅលើ សុខុមាលភាពពេញលេញទាំងផ្នែករូបរាងកាយ សុខភាពផ្លូវចិត្ត និងសង្គម មិនមែនគ្រាន់តែអវត្តមាននៃជម្ងឺ ឬភាពឈឺចាប់ប៉ុណ្ណោះទេ។ សុខភាពគឺជាសិទ្ធិមនុស្សមូលដ្ឋាន ហើយការទទួលបានសុខភាពកំរិតខ្ពស់បំផុតគឺជាគោលដៅសង្គមដ៏សំខាន់នៅទូទាំងពិភពលោក ដែលការសម្រេចអោយបានគោលដៅនេះ ទាមទារអោយមានសកម្មភាពរបស់វិស័យច្រើនដូចជា វិស័យសង្គម និងសេដ្ឋកិច្ចបន្ថែមទៅលើវិស័យសុខាភិបាល។

២. វិសមភាពនៃស្ថានភាពសុខភាពរបស់ប្រជាជន ពិសេសរវាងបណ្តាប្រទេសដែលអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍ ព្រមទាំងវិសមភាពដែលកើតមាននៅក្នុងបណ្តាប្រទេសទាំងនោះ គឺមិនអាចអោយយើងទទួលយកបានទាំងផ្នែកនយោបាយសង្គម និងសេដ្ឋកិច្ច ហើយនេះគឺជាការព្រួយបារម្ភរួមរបស់បណ្តាប្រទេសទាំងអស់។

៣. យោងទៅតាមគោលនយោបាយសេដ្ឋកិច្ចអន្តរជាតិថ្មី ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម គឺមានសារៈសំខាន់ជាមូលដ្ឋានដើម្បីទទួលបាននូវសុខភាពយ៉ាងពេញលេញសម្រាប់ទាំងអស់

គ្នា និង កាត់បន្ថយគម្លាតនៃស្ថានភាពសុខភាពរវាងប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍន៍។ ការលើកកំពស់និងការការពារសុខភាពរបស់ប្រជាជន គឺមានភាពចាំបាច់សម្រាប់ធ្វើអោយមាននិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម និងរួមចំណែក ធ្វើអោយ គុណភាពជីវិតមានភាពប្រសើរឡើង និងមានសន្តិភាពនៅលើពិភពលោក។

៤. ប្រជាជនមានសិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមជាលក្ខណៈបុគ្គល និងរួមគ្នានៅក្នុងការធ្វើផែនការនិងការអនុវត្តន៍ការថែទាំសុខភាពរបស់ពួកគេ។

៥. រដ្ឋាភិបាលមានទំនួលខុសត្រូវចំពោះសុខភាពរបស់ប្រជាជន ដែលសុខភាពនោះអាចបំពេញបានតាមរយៈយន្តការសង្គមនិងយន្តការផ្តល់សុខភាពគ្រប់គ្រាន់និងប្រកបដោយសមធម៌។ គោលដៅសង្គមចម្បងរបស់រដ្ឋាភិបាល អង្គការអន្តរជាតិ និងសហគមន៍ពិភពលោកទាំងមូលក្នុងទសវត្សរ៍នាពេលខាងមុខ គឺជាការទទួលបានដោយប្រជាជនទាំងអស់ក្នុងពិភពលោកនៅត្រឹមឆ្នាំ ២០០០ នូវកម្រិតសុខភាពមួយដែលអាចធ្វើអោយប្រជាជនដឹកនាំជីវិតរបស់ពួកគេប្រកបដោយផ្លែផ្កាសង្គម និង សេដ្ឋកិច្ច ។ ការថែទាំសុខភាពបឋម គឺជាគន្លឹះដើម្បីសម្រេចបានគោលដៅនេះ ដែលជាផ្នែកមួយនៃការអភិវឌ្ឍន៍ស្មារតីយុត្តិធម៌សង្គម។

៦. ការថែទាំសុខភាពបឋម គឺជាការថែរក្សាសុខភាពដ៏ចាំបាច់ដោយផ្អែកទៅលើការអនុវត្តន៍ការមានវិធីសាស្រ្តតាមបែបវិទ្យាសាស្រ្តនិងសង្គមដែលទទួលយកបាន និងបច្ចេកវិទ្យាដែលគ្រប់បុគ្គលនិងក្រុមគ្រួសារនៅក្នុងសហគមន៍អាចប្រើប្រាស់និងទទួលបានតាមរយៈការចូលរួមពេញលេញរបស់ពួកគេ ហើយនិងនៅក្នុងកម្រិតចំណាយមួយដែលសហគមន៍និងប្រទេសអាចមានលទ្ធភាពផ្គត់ផ្គង់បាន ដើម្បីអោយពួកគេអាចរក្សាថែទាំបាននូវការអភិវឌ្ឍន៍ស្មារតីនៃការទទួលខុសត្រូវ និងភាពឯករាជ្យរបស់ពួកគេដោយខ្លួនឯងនៅគ្រប់ដំណាក់កាល។ ការថែទាំសុខភាពបឋម បង្កើតបានជាផ្នែកមួយសំខាន់នៅក្នុងប្រព័ន្ធសុខាភិបាលរបស់ប្រទេសជាចំនុចស្នូលដែលត្រូវផ្តោតទៅលើ និងជាផ្នែកមួយនៃការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ច

ទាំងមូល របស់សហគមន៍។ វាគឺជាចំនុចដំបូងនៃទំនាក់ទំនងរបស់បុគ្គល គ្រួសារ និងសហគមន៍ជាមួយនឹងប្រព័ន្ធសុខាភិបាលជាតិ ការពាំនាំការថែទាំសុខភាពអោយនៅកាន់តែជិតកន្លែងដែលប្រជាជនរស់នៅ នឹងធ្វើការ ហើយវាគឺជាសមាធាតុដំបូងធ្វើអោយមានការបន្តនូវដំណើរការថែទាំសុខភាព។

៧. ការថែទាំសុខភាពបឋម

ក. ឆ្លុះបញ្ចាំង និងវិវត្តន៍ពីលក្ខខណ្ឌសេដ្ឋកិច្ច សង្គមវប្បធម៌ និង ចរិកលក្ខណៈនយោបាយរបស់ប្រទេស និងសហគមន៍របស់ខ្លួន ហើយផ្អែកលើលទ្ធផលចេញពីការសិក្សាស្រាវជ្រាវអំពីសេវាសុខភាព ជីវ-វេជ្ជសាស្ត្រ និងបទពិសោធន៍នៅក្នុងសុខភាពសាធារណៈ

ខ. ដោះស្រាយបញ្ហាសុខភាពសំខាន់ៗដែលមាននៅក្នុងសហគមន៍ ផ្តល់នូវការលើកទឹកចិត្តសេវាកម្មបង្ការ ការពារ ព្យាបាល និងស្តារនីតិសម្បទា

គ. រួមបញ្ចូលយ៉ាងហោចណាស់នូវៈ ការអប់រំទាក់ទងនឹងបញ្ហាសុខភាពទូទៅ និងវិធីសាស្ត្រនៅក្នុងការបង្ការការពារនិងការគ្រប់គ្រង ការលើកកម្ពស់ចំពោះការផ្គត់ផ្គង់ម្ហូបអាហារនិងអាហាររូបត្ថម្ភបានត្រឹមត្រូវ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជាមូលដ្ឋានអោយបានគ្រប់គ្រាន់ ការថែទាំសុខភាពមាតានិងទារករួមមានការធ្វើផែនការគ្រួសារ ការចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺឆ្លងចំបងៗ ការបង្ការនិងទប់ស្កាត់ជំងឺឆ្លងនៅតាមមូលដ្ឋាន ការព្យាបាលដោយត្រឹមត្រូវចំពោះជំងឺទូទៅ និងការរងរបួស និងការផ្តល់នូវថ្នាំចាំបាច់

ឃ. បន្ថែមពីលើវិស័យសុខាភិបាល ចូលរួមនៅក្នុងគ្រប់វិស័យ និងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍន៍សហគមន៍និងជាតិដែលពាក់ព័ន្ធទាំងអស់ ជាពិសេសក្នុងវិស័យកសិកម្ម ការចិញ្ចឹមសត្វ ស្បៀងអាហារ ឧស្សាហាកម្ម អប់រំ ជម្រក ការងារសាធារណៈ ទំនាក់ទំនង និងវិស័យផ្សេងៗទៀត ហើយនិងទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងដោយមានការសំរបសំរួលក្នុងវិស័យទាំងអស់នោះ។

ង. តម្រូវ និង លើកកម្ពស់ជាអតិបរមានូវភាពម្ចាស់ការនិងការចូលរួមរបស់សហាគមន៍ និង បុគ្គល ក្នុងការរៀបចំផែនការ ការចងក្រង ការប្រតិបត្តិការ និងការគ្រប់គ្រងការថែទាំសុខភាពបឋម ដោយប្រើប្រាស់អោយបានពេញលេញនូវធនធានក្នុងស្រុក ជាតិ និងធនធានដទៃទៀត ដែលមាន ហើយការអភិវឌ្ឍន៍តាមរយៈការអប់រំ ពង្រឹងសមត្ថភាពរបស់សហាគមន៍ដើម្បីចូលរួម

ច. មាននិរន្តរភាពដោយការធ្វើសហមារណកម្ម សមាហរណកម្ម ប្រពន្ធ័បញ្ជូនដែលប្រកបដោយលក្ខខណៈគាំទ្រគ្នាទៅវិញមកនិងមានតំណើរការ ដំណើរការ ដែលនេះដឹកនាំទៅរកភាពរីកចម្រើននៃការថែទាំសុខភាពទូលំទូលាយសម្រាប់ទាំងអស់គ្នា និងផ្តល់អាទិភាពដល់អ្នកដែលត្រូវការបំផុត

ឆ. នៅកំរិតមូលដ្ឋាន និងសេវាផ្ទេរបន្ត (កម្រិតពេទ្យបង្អែក) ពឹងផ្អែកលើបុគ្គលិកសុខាភិបាលរួមទាំងគ្រូពេទ្យ គិលានុបដ្ឋយាកាគិលានុបដ្ឋាយិកា ឆ្មប អ្នកជួយ និងអ្នកដែលធ្វើការតាមសហាគមន៍ ដាក់អោយអនុវត្តការងារ ព្រមទាំងគ្រូពេទ្យបុរាណផងដែរទៅតាមតម្រូវការ ធ្វើការបណ្តុះបណ្តាលអោយបានត្រឹមត្រូវទាំងផ្នែកសង្គមនិងបច្ចេកទេសដើម្បីធ្វើការជាក្រុមក្នុងការផ្តល់សេវាសុខភាព និងដើម្បីឆ្លើយតបទៅនឹងតំរូវការសុខភាពរបស់សហាគមន៍។

៨. រដ្ឋាភិបាលទាំងអស់គួរតែបង្កើតគោលនយោបាយជាតិ យុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពដើម្បីចាប់ផ្តើម និងទ្រទ្រង់ការថែទាំសុខភាពបឋម ជាផ្នែកមួយនៃប្រព័ន្ធសុខាភិបាលជាតិដ៏ទូលំទូលាយ ហើយមានការសម្របសម្រួលជាមួយវិស័យដទៃទៀត។ ចុងបញ្ចប់ វាចាំបាច់ណាស់នៅក្នុងការអនុវត្តន៍ឆន្ទៈនយោបាយ (អាចគេគិតថាជារឿងនយោបាយ) ដើម្បីប្រមូលធនធាននៅក្នុងប្រទេស និងដើម្បីប្រើប្រាស់ធនធានខាងក្រៅដែលមានអោយបានសមស្រប ។

៩. ប្រទេសទាំងអស់គួរតែសហការគ្នាក្នុងស្មារតីភាពជាដៃគូ និងបម្រើសេវាកម្មដើម្បីធានាអោយបាននូវការថែទាំសុខភាពភាពបឋមសម្រាប់មនុស្សគ្រប់រូប ដោយសារការទទួលបានសុខភាពរបស់ប្រជាជននៅក្នុងប្រទេសណាមួយនោះ ជាក្តីកង្វល់និងផលប្រយោជន៍ដោយផ្ទាល់របស់ប្រទេសដ៏ទៃទៀត។ នៅក្នុងបរិបទនេះ របាយការណ៍អង្គការសុខភាពពិភពលោក/យូនីសេហ្វ អង្គការសុខភាពពិភពលោក និងយូនីសេហ្វ (UNICEF) ស្តីពីការថែទាំសុខភាពបឋមគឺជាមូលដ្ឋានរឹងមាំសម្រាប់បន្តការអភិវឌ្ឍ ការអភិវឌ្ឍន៍និងប្រតិបត្តិការនៃការថែទាំសុខភាពបឋមនៅទូទាំងពិភពលោក។

១០. កម្រិតសុខភាពដែលអាចទទួលយកបានសម្រាប់មនុស្សទាំងអស់ក្នុងពិភពលោកនៅឆ្នាំ ២០០០ អាចសម្រេចបានតាមរយៈការប្រើប្រាស់អោយបានកាន់តែពេញលេញ និងប្រសើរនូវធនធានរបស់ពិភពលោក ដែលបច្ចុប្បន្ន ធនធានទាំងនោះត្រូវបានប្រើប្រាស់សម្រាប់ចំណាយទៅលើសព្វាវុធ និងជម្លោះយោធា។ គោលនយោបាយពិតប្រាកដ ស្តីពីឯករាជ្យភាព សន្តិភាព បញ្ឈប់ជម្លោះរវាងប្រទេសនិងការដកហូតសព្វាវុធ អាចធ្វើអោយមានការដាក់ចេញនូវធនធានបន្ថែម ប្រើសម្រាប់គោលបំណងសន្តិភាព ហើយជាពិសេសនោះគឺសម្រាប់បង្កើនល្បឿននៃការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចទៅលើផ្នែកថែទាំសុខភាពបឋមដែលជាផ្នែកមួយដ៏សំខាន់ដែលគួរទទួលបាននូវចំណែកនៃធនធានទាំងនោះ។

សន្និសីទអន្តរជាតិស្តីពីការថែទាំសុខភាពបឋម អំពាវនាវអោយមានសកម្មភាពនៅថ្នាក់ជាតិនិងអន្តរជាតិជាបន្ទាន់និងប្រកបដោយប្រសិទ្ធភាព ក្នុងការអភិវឌ្ឍន៍និងអនុវត្តន៍ អនុវត្តការថែទាំសុខភាពបឋមនៅទូទាំងពិភពលោក និងជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប្រកបដោយស្មារតីកិច្ចសហប្រតិបត្តិការខាងផ្នែកបច្ចេកទេស និងទៅតាមគោលនយោបាយសេដ្ឋកិច្ចអន្តរជាតិថ្មី។ វាជម្រុញអោយរដ្ឋាភិបាល អង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និងអង្គការអន្តរជាតិដទៃទៀត ព្រមទាំងភ្នាក់ងារពហុភាគី និងទ្វេភាគី អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារផ្តល់មូលនិធិ បុគ្គលិកសុខាភិបាលទាំងអស់ និងសហគមន៍ពិភពលោក

ទាំងមូល គាំទ្រការប្តេជ្ញាចិត្តរបស់ជាតិ និងអន្តរជាតិ ចំពោះការថែទាំសុខភាពបឋមនិងការបញ្ជូនបច្ចេកទេស និង ហិរញ្ញវត្ថុសម្រាប់ការថែទាំសុខភាពបឋម ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ សន្និសីទអំពាវនាវអោយគ្រប់អ្នកពាក់ព័ន្ធដែលមាននៅក្នុងការបរិយាយខាងលើទាំងអស់ សហការគ្នាក្នុងការណែនាំ អភិវឌ្ឍន៍ អភិវឌ្ឍ និងរក្សាថែទាំសុខភាពបឋម សមស្របទៅតាមស្មារតី និងខ្លឹមសារនៃសេចក្តីប្រកាសនេះ។